# ស្ព័ឡាក់ផ្ទូរ
# យប់ដំបូង

*សាឡ្យាម* បានធ្វើសេចក្ដីរាយការណ៍ថា៖ "លោកគ្រូខ្ញុំ មូឡា ហ្វាត់ហ៍ អ៊ុលី ស៊ូលតុន អ៊ុបាឌី បានថា៖ "ខ្ញុំតែងតែធ្វើស៊ូឡាត់ផ្ទះយប់ដំបូង រាល់ពេលដែលខ្ញុំទទួលដំណឹងមរណៈ ទោះជាខ្ញុំស្គាល់ឬមិនស្គាល់អ្នកនោះក៏ដោយ ។ មិនមានអ្នកណាដឹងទម្លាប់ខ្ញុំទេ លុះថ្ងៃមួយខ្ញុំបានជួបមិត្តម្នាក់ គាត់បានប្រាប់ខ្ញុំថា៖ "ខ្ញុំបានយល់ សប្តិឃើញអ្នកស្លាប់ថ្មីៗកាលពីយប់មិញ ។ ខ្ញុំបានសួរអំពីស្ថានការណ៍គាត់ក្រោយពីស្លាប់ ។ គាត់បានប្រាប់ខ្ញុំថាគាត់លំបាកខ្លាំងបណ្ដាលឲ្យគាត់ឈឺចាប់រហូតដល់ មូឡា ហ្វាត់ហ៍ អ៊ុលី អ៊ុបាឌី បានស៊ូឡាត់ឲ្យខ្ញុំ ។ ស៊ូឡាត់នេះឯងដែលធ្វើឲ្យខ្ញុំរួចពីការឈឺចាប់ ។ សូមអល់ឡោះហ៍អាណិតអាសូរលោកដែលបានប្រោសប្រណីដល់ខ្ញុំ ។" មិត្តខ្ញុំម្នាក់នេះបានសួរខ្ញុំថា៖ "អ្វីទៅស៊ូឡាត់នោះ ?" ខ្ញុំបានប្រាប់គាត់អំពីរបៀបធ្វើស៊ូឡាត់ផ្ទះយប់ដំបូង ។"[10]

[10] ដ្វារ អាស់-សាឡ្យាម ហ្វី ម៉ា យ៉ាតាអ៊ុល់ឡាគ្វូ ប៊ិល-រុយ៉ា វ៉ា អាល់-ម៉ាណាំ (دار السلام فيما يتعلق بالرؤيا والمنام), ក្បាលទី ២ ទំព័រ ៣៤៨ ។

## មគ្គផលបានពីស្ម៏ឡាត់នេះ

ព្រះសាស្តាﷺមានព្រះវចនៈអំពីមគ្គផលរបស់ស្ម៏ឡាត់នេះថា៖

قَالَ رَسُولُ اللَّهِ ص: لايأْتِى عَلَى الْمَيتِ سَاعَةٌ أَشَدُّ مِنْ أَوَّلِ لَيلَةٍ فَارْحَمُوا مَوْتَاكُمْ بِالصَّدَقَةِ فَإِنْ لَمْ تَجِدُوا فَلْيصَلِّ أَحَدُكُمْ رَكْعَتَينِ يقْرَأُ فِى الْأُولَى بِفَاتِحَةِ الْكِتَابِ مَرَّةً وَ قُلْ هُوَ اللَّهُ أَحَدٌ مَرَّتَينِ وَ فِى الثَّانِيةِ فَاتِحَةَ الْكِتَابِ مَرَّةً وَ أَلْهَاكُمُ التَّكَاثُرُ عَشْرَ مَرَّاتٍ وَ يسَلِّمُ وَ يقُولُ اللَّهُمَّ صَلِّ عَلَى مُحَمَّدٍ وَ آلِ مُحَمَّدٍ وَ ابْعَثْ ثَوَابَهَا إِلَى قَبْرِ ذَلِكَ الْمَيتِ فُلَانِ بْنِ فُلَانٍ فَيبْعَثُ اللَّهُ مِنْ سَاعَتِهِ أَلْفَ مَلَكٍ إِلَى قَبْرِهِ مَعَ كُلِّ مَلَكٍ ثَوْبٌ وَ حُلَّةٌ وَ يوَسَّعُ قَبْرُهُ مِنَ الضِّيقِ إِلَى يوْمِ ينْفَخُ فِى الصُّورِ وَ يعْطَى الْمُصَلِّى بِعَدَدِ مَا طَلَعَتْ عَلَيهِ الشَّمْسُ حَسَنَاتٍ وَ تُرْفَعُ لَهُ أَرْبَعُونَ دَرَجَةً.

"សម្រាប់អ្នកស្លាប់ ពុំមានអ្វីលំបាកជាងយប់ដំបូងនៅក្នុងផ្នូរទេ ។ ដូច្នេះចូរអស់លោកអាណិតអាសូរដល់បងប្អូនអ្នកស្លាប់របស់អស់លោក ចូរបរិច្ចាគទានឲ្យពួកគេ បើអស់លោកមិនអាចបរិច្ចាគទានបានទេ ចូរស្ម៏ឡាត់ឲ្យបងប្អូនអ្នកស្លាប់របស់អស់លោក ។ ពេលអស់លោកស្ម៏ឡាត់ឲ្យពួកគេ អល់ឡោះហ្ទ៍تعالىចាត់បញ្ជូនទេវតា ១000 អង្គមកឯផ្នូរអ្នកនោះ ។ ទេវតាមួយអង្គៗនាំសំលៀកបំពាក់មកឲ្យអ្នកនោះ ហើយពង្រីកផ្នូរអ្នកនោះរហូតដល់ថ្ងៃរស់ពីស្លាប់វិញ ។ អល់ឡោះហ្ទ៍នឹងប្រទានឲ្យអស់លោករាល់គ្នាដែលបានធ្វើស្ម៏ឡាត់នោះ នូវមគ្គផលច្រើនស្មើនឹងចំនួនវត្ថុនានាដែលថ្ងៃរះមកប៉ះនៅពេលព្រឹក ហើយព្រះអង្គបង្កើនបុណ្យសក្តិអស់លោកដល់ទៅ ៤0 ថ្នាក់ ។"

## ភ័ស្តុតាងបញ្ជាក់រឿងស្ម៏ឡាត់នេះ

លោក មូហាដ្ឌ៉ីស្ស អាល់-នូរី (مُحدّث النوري) នៅក្នុងសៀវភៅលោក *ដារ អាល់-*



ស្ម៏ឡាត់ផ្នូរយប់ដំបូង (صَلاة ليلة الدّفن) ជាស្ម៏ឡាត់តាមជម្រើស (គឺមុសតាហាប់) មិនមែនស្ម៏ឡាត់វ៉ាយ៉ិបទេ ។ ស្ម៏ឡាត់នេះមានឈ្មោះផ្សេងទៀត ដូចជា "ស្ម៏ឡាត់អំណោយ" ឬ "ស្ម៏ឡាត់រន្ធត់" ជាដើម ។ គឺជាស្ម៏ឡាត់ដែលគេធ្វើឧទ្ទិសឲ្យទៅអ្នកស្លាប់ ក្នុងយប់ទីមួយក្រោយពីបានបញ្ចុះសពក្នុងផ្នូរ ។ ពេលវេលាគួរឲ្យធ្វើស្ម៏ឡាត់នេះគឺពេលចុងយប់ ក្រោយពីបានស្ម៏ឡាត់ អ៊ីស្ហាអ៍រួច ក្នុងថ្ងៃបញ្ចុះសពតែម្តង ។

## ឈ្មោះផ្សេងៗរបស់ស្ម៏ឡាត់នេះ

គេហៅស្ម៏ឡាត់នេះច្រើនបែប ដូចជា "ស្ម៏ឡាត់ អាល់-ហាឌីយ៉ាស្ទ (صَلاة الهَديّة)[1] គឺស្ម៏ឡាត់អំណោយ, ស្ម៏ឡាត់ ឡៃឡាតុដ-ដ្ហាហ្វ៍ន៍ (صَلاة ليلة الدّفن)[2] គឺស្ម៏ឡាត់យប់បញ្ចុះសព, ស្ម៏ឡាត់ អាល់-វ៉ាស្ហ៍ស្ហាស្ទ (صَلاة الوَحشَة)[3] គឺស្ម៏ឡាត់រន្ធត់ ។
គេហៅស្ម៏ឡាត់នេះថា "ស្ម៏ឡាត់រន្ធត់" ពីព្រោះអ្នកដែលបានចាកចោលលោកនេះមិនទាន់ស្គាល់ មិនទាន់ស៊ាំនឹងផ្នូរ (គឺលោកមុខ) នៅឡើយទេ អ្នកនោះអាចភ័យខ្លាចក្នុងការឆ្លងពីលោកនេះទៅកាន់លោកផ្នូរនោះ ។ ស្ម៏ឡាត់នេះអាចការពារខ្លួនអ្នកនោះបានដោយសង្ឃឹមថាអល់ឡោះហ្ទ៍នឹងអើពើអ្នកនោះ កុំឲ្យអ្នកនោះភ័យរន្ធត់ ។ ការពិតស្ម៏ឡាត់នេះជាស្ម៏ឡាត់សូមកុំឲ្យភ័យខ្លាច មិនមែនស្ម៏ឡាត់ឲ្យភ័យរន្ធត់ទេ ។

## វិធីស្ម៏ឡាត់

យោលតាមប្រភពព័ត៌មាននិងក្បួនអនុវត្តិហ្វ៊ីកោ្ហះហ្ទ៍ គេអាចធ្វើស្ម៏ឡាត់ឲ្យ

---

[1] វ៉ាសាអ៊ីល អាល់-ស្ហ៊ីអាស្ទ (وسائل الشيعة), ក្បាលទី ៧ ទំព័រ ១៦៨ ។

[2] អាល់-អ៊ូរវ៉ាតុល់-វុស្ហ៊្គ៏ (العُروَة الوُثقى), ក្បាលទី ៣ ទំព័រ ៤0១ ។

[3] តាស្ហ៍រៀរ អាល់-វ៉ាស៊ីឡាស្ទ (تحرير الوسيلة), ក្បាលទី ១ ទំព័រ ១0៨ ។

ម៉ាយិតក្នុងយប់ដំបូងបានពីរបែបគឺ៖

-ក្នុងរ៉ក់អ៊ាត់ទី ១ សូត្រស៊ូរ៉ោះត៍ អាល់-ហ៊ាំដ៍ មួយដង សូត្រស៊ូរ៉ោះត៍ តៅហ៊ីដ្ធ ២ ដង ។ ក្នុងរ៉ក់អ៊ាត់ទី ២ សូត្រស៊ូរ៉ោះត៍ អាល់-ហ៊ាំដ៍ មួយដង សូត្រស៊ូរ៉ោះត៍ អាត់-តាកាស៊្ហ៊ូរ៍ (១០២) ១០ ដង ។ ក្រោយពីបានឲ្យសាឡាមរួច សូត្រដូចតទៅគឺ៖

اَللّهُمَّ صَلِّ عَلى مُحمّدٍ وَ آلِ مُحمّدٍ وَ ابْعَثْ ثَوابَها اِلى قَبرِ فلان بن فلان

អល់ឡ៉ហ៊ុមម៉ា ស្វល់លី អ៊ាឡា មូហ៊ាំម៉ាដ់ វ៉ា អាលី មូហ៊ាំម៉ាដ់ វ៉ាប់អាស៊្ហ ស្ហ៊ាវ៉ាបាហ្វា អ៊ីឡា កូប់រី ហ្វ៊ូឡាន់ ប៊ិន ហ្វ៊ូឡាន់ ។

*សូមអល់ឡោះហ្វ៍ប្រសិទ្ធិពរជ័យសិរីសួស្តីដល់មូហ៊ាំម៉ាដ៍ និងព្រះរាជកុលដ្ឋានរបស់មូហ៊ាំម៉ាដ៍ និងសូមព្រះអង្គប្រទានរង្វាន់តបស្នងដល់បុគ្គលក្នុងផ្នូរ... ។*

ឲ្យថាឈ្មោះរបស់អ្នកស្លាប់និងឈ្មោះរបស់ឪពុកអ្នកស្លាប់នេះ ជួស ហ្វ៊ូឡាន់ ប៊ិន ហ្វ៊ូឡាន់ (فلان بن فلان) ឧទាហរណ៍៖ យ៉ាម៉ាល់ (អ្នកស្លាប់) ប៊ិន ការីម (ឪពុករបស់អ្នកស្លាប់) ។

-ក្នុងរ៉ក់អ៊ាត់ទី ១ ក្រោយពីបានសូត្រស៊ូរ៉ោះត៍ អាល់-ហ៊ាំដ៍ សូត្រស៊ូរ៉ោះត៍ អាយ៉ាត់ គូរស៊ី ១ ដង ។ ក្នុងរ៉ក់អ៊ាត់ទី ២ ក្រោយពីបានសូត្រស៊ូរ៉ោះត៍ អាល់-ហ៊ាំដ៍ សូត្រស៊ូរ៉ោះត៍ អាល់-ក្វ៉ដ្ឋ៍ ១០ ដង ។ នៅចុងក្រោយ រួចពីឲ្យសាឡាមហើយ ឲ្យសូត្រដូចតទៅគឺ៖

اَللّهُمَّ صَلِّ عَلى مُحمّدٍ وَ آلِ مُحمّدٍ وَ ابْعَثْ ثَوابَها اِلى قَبرِ فلان بن فلان

អល់ឡ៉ហ៊ុមម៉ា ស្វល់លី អ៊ាឡា មូហ៊ាំម៉ាដ់ វ៉ា អាលី មូហ៊ាំម៉ាដ់ វ៉ាប់អាស៊្ហ ស្ហ៊ាវ៉ាបាហ្វា អ៊ីឡា កូប់រី ហ្វ៊ូឡាន់ ប៊ិន ហ្វ៊ូឡាន់ ។

*សូមអល់ឡោះហ្វ៍ប្រសិទ្ធិពរជ័យសិរីសួស្តីដល់មូហ៊ាំម៉ាដ៍ និងព្រះរាជកុលដ្ឋានរបស់មូហ៊ាំម៉ាដ៍ និងសូមព្រះអង្គប្រទានរង្វាន់តបស្នងបុគ្គលក្នុងផ្នូរ... ។*



ឲ្យថាឈ្មោះរបស់អ្នកស្លាប់និងឈ្មោះរបស់ឪពុកអ្នកស្លាប់នេះ ជួស ហ្វ៊ូឡាន់ ប៊ិន ហ្វ៊ូឡាន់ (فلان بن فلان) ឧទាហរណ៍៖ យ៉ាម៉ាល់ (អ្នកស្លាប់) ប៊ិន ការីម (ឪពុករបស់អ្នកស្លាប់)[4] ។

## ច្បាប់ហ្វ៊ីកោ្ហ៍ពាក់ព័ន្ធនឹងស្វ៉ឡាត់នេះ

នេះគឺយោបល់ខ្លះៗអំពីស្វ៉ឡាត់នេះ គឺ៖

១-គេអាចធ្វើស្វ៉ឡាត់នេះបាន ចាប់តាំងពីពេលបញ្ចុះសពរហូតដល់ពេលមុនថ្ងៃរះនៃថ្ងៃថ្មី ។ តែគប្បីធ្វើស្វ៉ឡាត់នេះក្រោយស្វ៉ឡាត់វ៉ាយិបចុងក្រោយបង្អស់នៃថ្ងៃបញ្ចុះសព[5] ។

២-បើសពត្រូវបញ្ចុះយឺតពេល (ច្រើនថ្ងៃក្រោយពីស្លាប់) គប្បីរង់ចាំ ហើយធ្វើស្វ៉ឡាត់ក្រោយពីបានបញ្ចុះសពរួច[6] ។

៣-អាចធ្វើស្វ៉ឡាត់នេះបានច្រើនដងដោយមនុស្សដដែល ជាអំណោយដល់អ្នកស្លាប់[7] ។

៤-បើភាន់ច្រឡំ សូត្រស្វ៉ឡាត់មិនត្រឹមត្រូវ អាចស្វ៉ឡាត់សាឡើងវិញបាន[8] ។

៥-អនុញ្ញាតឲ្យជួលមនុស្សធ្វើស្វ៉ឡាត់ឲ្យអ្នកស្លាប់បាន ។ ក៏ប៉ុន្តែត្រូវប៉ងធ្វើល្អក្នុងទង្វើនេះ និងជាការជួយដល់អ្នកទាល់ក្រ[9] ។

---

[4] តាស់រៀរ អាល់-វ៉ាស៊ីឡាស់ (تحرير الوسيلة), ក្បាលទី ១ ទំព័រ ១០៨ ។

[5] ក្បួនអនុវត្តិរបស់ អាយ៉ាទុលឡោះហ្វ៍ យូមែនី ទំព័រ ១០០ សំណួរ ៦៣៩ ។

[6] ក្បួនអនុវត្តិរបស់ អាយ៉ាទុលឡោះហ្វ៍ យូមែនី ទំព័រ ១០០ សំណួរ ៦៤០ ។

[7] លោក គុម្មី, *អាល់-ក៏យ៉ាស់ អាល់-ក៏សាវី ហ្វី...*, ក្បាលទី ១ ទំព័រ ៦២៦២ ។

[8] លោក គុម្មី, *អាល់-ក៏យ៉ាស់ អាល់-ក៏សាវី ហ្វី...*, ក្បាលទី ១ ទំព័រ ៦២៦២ ។

[9] តាស់រៀរ អាល់-វ៉ាស៊ីឡាស់ (تحرير الوسيلة), ក្បាលទី ១ ទំព័រ ១០៩ ។